**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ការរកឃើញ៤ករណីថ្មីទៀត ជាជនជាតិខ្មែរឥស្លាម២នាក់នៅខេត្តព្រះវិហារ បុរសជនជាតិខ្មែរមកពីប្រទេសបារាំង និងជាកូនរបស់ជនជាតិបារាំងអាយុ ៣៥ ឆ្នាំ វិជ្ជមានវីរុសកូវីដ១៩

មកដល់ម៉ោង២១:០០ យប់ នៃថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២០ ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ ឲ្យបានជ្រាបថា លទ្ធផលពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជាបានបង្ហាញ វិជ្ជមានវីរុសកូវីដ១៩ ចំនួន៤នាក់ បន្ថែមទៀត ដែលមានករណីដូចខាងក្រោមនេះ៖

- ករណីកូនរបស់បុរសជនជាតិបារាំងឈ្មោះ Michelle Dizon Cruz អាយុ ៣៥ ឆ្នាំ ដែលមានវីរុសកូវីដ១៩ កូននេះមានអាយុ០៤ខែ បានរកឃើញវិជ្ជមានវីរុសកូវីដ១៩ នៅពេលនេះ ហើយបានរៀបចំយកទៅដាក់ព្យាបាលនៅមន្ទីរពេទ្យកុមារជាតិ។ រីឯម្តាយកូននេះវិញ អវិជ្ជមានវីរុសកូវីដ១៩
- បុរសជនជាតិខ្មែរ ០១ នាក់ ក្រោយពីវិលត្រឡប់មកពីប្រទេសបារាំងវិញ មានលទ្ធផលតេស្ត វិជ្ជមានវីរុសកូវីដ១៩ ដែលតម្រូវឲ្យនៅព្យាបាលក្នុងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត
- ខ្មែរឥស្លាមចំនួន០២នាក់នៅខេត្តព្រះវិហារ (អាយុ ៣៥ ឆ្នាំម្នាក់ និង ៣៩ ឆ្នាំម្នាក់) វិជ្ជមានវីរុសកូវីដ១៩។ នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០ ពួកគាត់ចំនួន១០នាក់ បានវិលត្រឡប់មកខេត្តព្រះវិហារវិញ បន្ទាប់ពីបានទៅចូលរួមពិធីសាសនានៅជិតទីក្រុងកូឡាឡាំពួរនៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០។ នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២០ មានការផ្តល់ព័ត៌មានមកថាអ្នកចូលរួមនៅក្នុងពិធីនោះនៅប្រទេសម៉ាឡេស៊ី មានអ្នកវិជ្ជមានវីរុសកូវីដ១៩។ បន្ទាប់មកមន្ទីរសុខាភិបាលខេត្តព្រះវិហារ បានស្រាវជ្រាវរកឃើញបុគ្គលដែលវិលត្រឡប់មកវិញទាំង១០នាក់នោះ ហើយបានយកសំណាកវត្ថុវិភាគចំនួន៨នាក់នៅថ្ងៃដដែល (ដោយ០១នាក់ បានចេញទៅស្ទឹងត្រែង ហើយមន្ទីរសុខាភិបាលខេត្តស្ទឹងត្រែងបានយកសំណាកវត្ថុវិភាគពីបុគ្គលនេះរួចហើយដែរនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២០ និងម្នាក់ទៀត មន្ទីរសុខាភិបាលខេត្តព្រះវិហារ នឹងយកសំណាកវត្ថុវិភាគនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០)។ ជាលទ្ធផលពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា បានបង្ហាញថា ក្នុងចំណោម ៨នាក់នោះ មានពីរនាក់ វិជ្ជមានវីរុសកូវីដ១៩។ បុគ្គលដែលវិជ្ជមានវីរុសកូវីដ១៩ទាំងពីរនាក់នេះ ក្រុមគ្រូពេទ្យនៃមន្ទីរសុខាភិបាលខេត្តព្រះវិហារ កំពុងចាត់ចែងរៀបចំយកមកដាក់ព្យាបាលនៅមន្ទីរពេទ្យខេត្តព្រះវិហារ។ រីឯអ្នក៨នាក់អវិជ្ជមានកូវីដ១៩នោះ ត្រូវដាក់ឲ្យនៅតាមដានសុខភាពផ្ទាល់ខ្លួនចំនួន១៤ថ្ងៃ។



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

ក្រុមការងាររបស់ក្រសួងសុខាភិបាល កំពុងតែធ្វើកិច្ចការស្រាវជ្រាវជាបន្តទៀត ហើយនឹងបន្តជម្រាបជូនដល់បងប្អូនសាធារណជន ប្រសិនបើមានរកឃើញករណីវិជ្ជមានវីរុសកូវីដ១៩ ថ្មីណាផ្សេងទៀត។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវឌ្ឍនៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃអាទិត្យ ៧រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២០

វេជ្ជបណ្ឌិត **ឱ វណ្ណឌីន**
រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យ ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា